## IV) អវសានបញ្ញត្តិ:

### ១) ការពិន័យមិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ឬវិសមាមាត្រ

ការផាកពិន័យលើការរំលោភច្បាប់ណាមួយ អាចផ្ទុយពីរដ្ឋធម្មនុញ្ញ នៅពេលដែលការហាមឃាត់បំពានរដ្ឋធម្មនុញ្ញដែរ ពីព្រោះ ការប្រព្រឹត្តិមួយចំនួន មិនគួរត្រូវហាមឃាត់ទាល់តែសោះ ។

ឧទាហរណ៍:

សកបរិវត្តន៍ (អត្ថបទ = version) នៃសកបរិវត្តន៍ដំបូងៗនៃច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល និងសមាគម បានបញ្ចូលមាត្រាមួយ ដែលចែងយ៉ាងច្បាស់អំពីការដាក់ទណ្ឌកម្មចំពោះការមិនចុះឈ្មោះសមាគមជាមួយអាជ្ញាធរ ។ ដោយវាបំពានលើសេរីភាពនៃការបង្កើតសមាគម ដើម្បីទាមទារកាចុះឈ្មោះបែបបង្ខំនោះវាពិតជាបំពានលើសេរីភាពនេះ ក្នុងការដាក់ទណ្ឌកម្មលើការលុបចោលនៃការចុះឈ្មោះនេះ ។

ក្រៅពីនេះ ការដាក់ទោសដូចនេះ អាចធ្វើឡើងដោយគ្មានការព្រួយបារម្ភទេ ប៉ុន្តែ កំរិតនៃការដាក់ទោសអាចខ្លាំងក្លាពេក ។ ឧទាហរណ៍ វាអាចបំពានលើសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ស្តីពីដំណើរការសមស្របក្នុងការដាក់ទោសលើរាល់ការបំពាន ដោយគ្មានការបែងចែកទៅតាមកំរិតធ្ងន់ធ្ងរនៃការបំពាននោះឡើយ ។

ឧទាហរណ៍:

ការជាប់ពន្ធនាគារជាអតិបរមាប្រាំឆ្នាំសំរាប់ការបំពានច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ ដូចមានចែងក្នុងមាត្រា២០ នៃពង្រាងច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ហាក់ដូចជាមិនសមាមាត្រដោយបញ្ញត្តិនេះ មិនពិចារណាលើការកើតមានករណីបំពាននេះតាមទ្រង់ទ្រាយតូចៗឡើយ ។

### ២) ពេលវេលាមិនគ្រប់គ្រាន់ និងអន្តរប្បញ្ញត្តិ:

នៅផ្នែកបញ្ចប់នៃច្បាប់នីមួយៗ គេអាចរកឃើញនូវបទបញ្ញត្តិនានា ដែលទាក់ទងនឹងសំនួរថាតើច្បាប់នេះ ត្រូវចូលជាធរមាននៅពេលណា? ប្រសិនបើចាំបាច់ មានបទបញ្ញត្តិមួយចំនួនផងដែរ ដែលកំណត់នូវមធ្យោបាយគ្រប់គ្រងសិទ្ធិ និងករណីយកិច្ចនៅក្នុងនីតិវិធីរដ្ឋបាលជាប់ៗគ្នា ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលច្បាប់ថ្មីប្រហែលជានឹងផ្លាស់ប្តូរមុខតំណែងច្បាប់ទាំងអស់របស់បុគ្គល និងអាជ្ញាធរដែលពាក់ព័ន្ធទាំងនេះ ។

ទាក់ទងនឹងពេលវេលា គេគួរតែផ្តល់អនុសាសន៍ឱ្យមាន "ប្រការថ្ងៃលិច"[២៩] មួយ ដែលកំណត់នូវរយៈពេលមានប្រសិទ្ធភាពនៃច្បាប់ថ្មី ។ នោះមានន័យថា ច្បាប់កំណត់ថា ច្បាប់នេះនឹងផុតកំណត់ដោយស្វ័យប្រវត្តិនៅកាលបរិច្ឆេទណាមួយ ។ បញ្ញត្តិនេះអាចមានការចាំបាច់ ដើម្បីកំណត់នូវប្រសិទ្ធភាពរបស់ច្បាប់មួយ និងដើម្បីជំរុញឱ្យអ្នកធ្វើច្បាប់ធ្វើការពិចារណាលើច្បាប់ឡើងវិញ ជាពិសេសនៅពេលដែលអ្នកធ្វើច្បាប់មិនមានសមត្ថភាពគ្រប់គ្រាន់នៅពេលបច្ចុប្បន្ន ដើម្បីព្យាករនូវប្រសិទ្ធភាពដែលច្បាប់នោះនឹងមាន ។ នេះនឹងបង្កើននីត្យានុកូលភាពបែបលទ្ធិប្រជាធិបតេយ្យនៃច្បាប់មួយ ជាពិសេសនៅក្នុងករណី នៅពេលដែលស្ថានភាពពុំស្ថិតស្ថេរ ឬគេអាចព្យាករបានថា ចំណុចចាប់ផ្តើមសំរាប់ច្បាប់នោះអាចមានការប្រែប្រួលនៅពេលអនាគត ។ វាអនុញ្ញាតឱ្យអ្នកធ្វើច្បាប់ ធ្វើការពិសោធន៍មួយជាមួយនឹងប្រសិទ្ធិភាពដែលមានកំរិតនេះ ។ ប៉ុន្តែ គេត្រូវធានាថា ពេលវេលាមិនត្រូវចង្អៀតពេកទេ ព្រោះបើមិនដូច្នោះទេ ច្បាប់មិនអាចអភិវឌ្ឍបានពេញលេញនូវមុខងារមគ្គុទ្ទេសក៍ និងកសាងសន្តិភាពបានឡើយ ព្រមទាំងនឹងបាត់បង់ការគោរពក្នុងចំណោមប្រជាពលរដ្ឋទៀតផង ។

---

[២៩] ចំពោះសេចក្តីលំអិតស្តីពីប្រការបែបនេះ សូមមើល ប៉ាទ្រីសៀ បារ (Patricia Baars) ស្តីពី "ការតាក់តែងច្បាប់" ទំព័រទី ៨០ ។ សូមមើលផងដែរ : មូលនិធិខន់រ៉ាដ់ អាដេណូអឺរ សៀវភៅស្តីពី "ការធ្វើពង្រាងច្បាប់ និងនីតិកម្ម" ទំព័រទី ៥៩ ។

ឧទាហរណ៍:

ច្បាប់មួយដែលកំណត់នូវរយៈពេលតែមួយឆ្នាំប៉ុណ្ណោះ តាមធម្មតា ផ្តល់នូវពេលវេលាមួយចង្អៀតជ្រុល ពីព្រោះ ក្នុងកំឡុងរយៈពេលដ៏ខ្លីដូចនេះ គេស្ទើរតែមិនអាចទទួលបានទិន្នន័យប្រកបដោយសុពលភាពគ្រប់គ្រាន់ សំរាប់ការវាយតម្លៃផង ។

ពាក់ព័ន្ធនឹងអន្តរប្បញ្ញត្តិ អ្នកធ្វើច្បាប់ត្រូវគិតថា តួនាទីផ្លូវច្បាប់ដែលគេបានទទួលរួចហើយក្នុងកំឡុងពេលដំណើរការរដ្ឋបាលជាប់ៗគ្នាមួយ ដូចជា សិទ្ធិក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិនោះ មិនត្រូវបានកាត់ផ្តាច់យ៉ាងរហ័សដោយច្បាប់ថ្មី ដោយគ្មានការសងជំងឺចិត្តឡើយ ។ លើសពីនេះទៀត គេត្រូវតែធានាថា នៅសល់ពេលវេលាគ្រប់គ្រាន់សំរាប់បុគ្គលដែលទទួលរងផលប៉ះពាល់ដោយច្បាប់ថ្មី ដើម្បីរៀបចំការដកតួនាទី និងការធ្វើផែនការរបស់ពួកគេ និងកែសម្រួលពាណិជ្ជកម្ម ឬអាជីព ឬកិច្ចការឯកជនរបស់ពួកគេ ទៅតាមការកំណត់ថ្មីដែលនឹងកើតមានឡើង ។ ឧទាហរណ៍ គេត្រូវតែធានាថា លិខិតអនុញ្ញាតមិនផុតកំណត់ពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារប្រសិទ្ធិភាពនៃច្បាប់ថ្មីឡើយ ។ ប្រសិនបើរយៈពេលនៃការកែសម្រួលបែបនេះ មិនត្រូវបានគេផ្តល់ឱ្យទេនោះ ច្បាប់នឹងដាក់កំហិតថ្មី ដែលអាចបំពានលើគោលការណ៍នៃភាពសមាមាត្រ ។

ឧទាហរណ៍:

- មាត្រា៣៩០ ឃ្លាទី១ ក្រមការងារ ធានាថា ក្រមនេះអាចអនុវត្តបានចំពោះកិច្ចសន្យាការងាររបស់បុគ្គលទាំងអស់ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យានោះមានប្រសិទ្ធភាព ។ ប៉ុន្តែ មាត្រា៣៩០ ឃ្លាទី២ នៃក្រមការងារធានាថា និយោជិតមិនបាត់បង់អត្ថប្រយោជន៍នៃកិច្ចសន្យារបស់គេឡើយ ក្នុងករណីដែលកិច្ចសន្យាទាំងនេះ ត្រូវបានធ្វើឡើងមុនច្បាប់ថ្មី ហើយមានការអនុគ្រោះច្រើន អ្វីដែលត្រូវបានទាមទារនៅក្រោមក្រមការងារថ្មី ។
- មាត្រា៣៩២ I ២ នៃក្រមការងារ ចែងច្បាស់ថា អង្គការចាត់តាំងរបស់កម្មករ និងនិយោជក អាចចុះហត្ថលេខាលើកិច្ចព្រមព្រៀងការងាររួមក្នុងកំឡុងរយៈពេលអន្តរកាល ថែមទាំងនៅពេលដែលកិច្ចព្រមព្រៀងទាំងនេះ មិនទាន់ត្រូវបានទទួលស្គាល់ទាំងស្រុងស្របតាមច្បាប់ថ្មីទៀតផង ។ ប៉ុន្តែ ប្រសិទ្ធិភាពនៃកិច្ចព្រមព្រៀងទាំងនេះ បញ្ចប់ក្រោយពីរយៈពេលមួយឆ្នាំ ហើយកិច្ចព្រមព្រៀងថ្មី អាចធ្វើបានដោយយោងទៅតាមប្រការនានានៃច្បាប់ថ្មីតែប៉ុណ្ណោះ ។

ដូច្នេះ មាត្រាទាំងពីរនេះធានាថា កម្មករមិនទទួលរងការខាតបង់ផ្នែកហិរញ្ញវត្ថុ ដោយការអនុម័តច្បាប់ថ្មីទេ ហើយថែមទាំងមិនបាត់បង់សមត្ថភាពរបស់ខ្លួន ក្នុងការចរចាជាមួយនិយោជកក្នុងកំឡុងរយៈពេលអន្តរកាលទៀតផង ។

### ៣) ប្រការចែងពីការធ្វើមោឃភាពមិនច្បាស់លាស់[៣០]

អ្វីដែលមិនច្បាស់លាស់ គឺជាបញ្ញត្តិសាមញ្ញទាំងឡាយនៅផ្នែកខាងចុងនៃអត្ថបទច្បាប់កម្ពុជាទាំងឡាយដែលជាទូទៅប្រកាសនូវ "បញ្ញត្តិច្បាប់ទាំងឡាយដទៃទៀតដែលមិនសមស្រប" ទុកជានិរាករណ៍ ។ ត្រង់ចំណុច

[៣០] សំរាប់ការអានបន្ថែមស្តីពីប្រធានបទនេះ សូមមើល ប៉ាទ្រីស្សៀ បារ (Patricia Baars) ស្តីពី "ការការតាក់តែងច្បាប់" ទំព័រទី ៧១ ។

នេះធ្វើឱ្យមានភាពមិនច្បាស់លាស់ចំពោះអ្នកអាន និងអ្នកដែលជាកម្មវត្ថុនៃច្បាប់ ថាតើបញ្ញត្តិផ្សេងៗទៀតនៃច្បាប់ មួយណាដែលនៅជាធរមាន និងមួយណាដែលមិននៅជាធរមាន ។ ដូច្នេះ វាត្រូវការការពិពណ៌នាឱ្យបានច្បាស់លាស់ថា តើអត្ថបទច្បាប់ណាមួយពិតប្រាកដត្រូវបានចាត់ទុកជានិរាករណ៍ ។

ឧទាហរណ៍:

មាត្រា២៩ នៃពង្រាងច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល និងសមាគម គ្រាន់តែចែងជាទូទៅថា: "គ្រប់បញ្ញត្តិទាំងអស់ដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជាមោឃៈ" ។ ប្រការដែលមិនច្បាស់ ដូចគ្នានេះក៏អាចរកឃើញនៅក្នុង មាត្រា៣៩៥ នៃក្រមការងារ ដែលចែងថា: "បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍" ។

## ឃ) លក្ខខណ្ឌតម្រូវទូទៅសំរាប់ផ្នែកទាំងអស់របស់ច្បាប់:

### I) ភាសាដែលអាចយល់បាន:

ការជ្រើសរើសការប្រើពាក្យត្រឹមត្រូវនៅក្នុងអត្ថបទច្បាប់ គឺជាឧបសគ្គមួយដ៏ធំបំផុតក្នុងចំណោមឧបសគ្គធំៗជាច្រើន ។ នៅក្នុងសកបរិវត្តនីគំរូ អត្ថបទច្បាប់គួរតែអាចយល់បានសំរាប់ពលរដ្ឋខ្មែរគ្រប់រូប ដែលចេះអាន និងចេះសរសេរ ។ ប្រយោគខ្លីហើយច្បាស់ ការជៀសវាងការប្រើពាក្យដដែលៗ និងការប្រើពាក្យបច្ចេកទេសច្រើនពេកគួរតែយកធ្វើជាវិធាន ។ នៅមានគោលការណែនាំ និងវិធានជច្រើនទៀតត្រូវបានបោះពុម្ពផ្សាយ និងមិនអាចពិភាក្សានៅទីនេះឱ្យបានពិស្តារលំអិតឡើយ[៣១] ។

### II) ការប្រើពាក្យសមហេតុផល (មិនត្រូវមានពាក្យមិនស៊ីសង្វាក់គ្នា ឬដែលមានភាពផ្ទុយគ្នាឡើយ):

ពាក្យនៅក្នុងច្បាប់ គួរតែត្រូវបានប្រើឱ្យដូចគ្នាជានិច្ច ។ ពាក្យដែលស្រដៀងគ្នា ប៉ុន្តែ យ៉ាងណាក៏ដោយក៏ជាពាក្យខុសគ្នា មិនគួរយកមកប្រើនៅក្នុងបទប្បញ្ញត្តិតែមួយឡើយ ។

ឧទាហរណ៍:

វាបង្កឱ្យមានការភ័ន្តច្រឡំយ៉ាងខ្លាំង ក្នុងការប្រើពាក្យទាំងឡាយដូចជា "ការនេសាទ" , "ជលផល" "ព្រំដែននេសាទដែលត្រូវបានការពារ" , "ដែននេសាទ" និង "ដែននេសាទដែលត្រូវការការពារ" នៅក្នុងច្បាប់តែមួយ (ដូចជានៅក្នុងពង្រាងច្បាប់ជលផល) ។

សន្ទានុក្រម ឬនិយមន័យនៃពាក្យយ៉ាងហោចណាស់អាចជួយកាត់បន្ថយការភ័ន្តច្រឡំបាន ។ ប្រសិនបើអ្នកធ្វើច្បាប់ និយាយ ពីវត្ថុដូចគ្នា ពួកគេគួរតែប្រើពាក្យដូចគ្នា ។

ឧទាហរណ៍:

ពួកគេមិនត្រូវប្រើពាក្យថា "ប្រាក់បៀវត្សរ៍" និង "ប្រាក់ឈ្នួលរបស់និយោជិត" នៅក្នុងអត្ថបទតែមួយឡើយ ប្រសិនបើ ពួកគេមិនចង់បង្ហាញនូវភាពខុសគ្នារវាងពាក្យទាំងពីរនេះទេនោះ ។ បើមិនដូច្នោះទេ អ្នកអានអាចចាប់អារម្មណ៍ថា ច្បាប់ចង់និយាយពីអ្វីមួយផ្សេងពីគ្នា ។

[៣១] សូមមើល : មូលនិធិខនរ៉ាដ អាដេណូអឺរ សៀវភៅស្តីពី "ការធ្វើពង្រាងច្បាប់" ទំព័រទី ៦៨-៧១ និងប៉ាទ្រីស្សៀ បារ (Patricia Baars) ស្តីពី "ការតាក់តែងច្បាប់" ទំព័រទី ៨៣-៩០ ។